**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ**
**អគ្គលេខាធិកាដ្ឋាន គ.ជ.ភ១.ផ១.**
លេខ.........១០១........គ.ជ.ភ១.ផ១.

ថ្ងៃ.....ច័ន្ទ.....៧ រោច.....ខែ.មិគសិរ..ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី.....០៧....ខែ......ធ្នូ.........ឆ្នាំ២០២០

# របាយការណ៍សមិទ្ធផល និងសកម្មភាពការងារ
# អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
# ប្រចាំខែវិច្ឆិកា ឆ្នាំ ២០២០

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ តាមរយៈព្រះរាជក្រឹត្យលេខនស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រធាន និង **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី សុខ អាន** ជាអនុប្រធាន។ នៅឆ្នាំ២០១៣ ការងារជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវបានធ្វើសមាហរណកម្មឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ដោយមាន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី** ជាប្រធាន។ ជាបន្តបន្ទាប់ ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិនេះក៏ត្រូវបានធ្វើវិសោធនកម្មដោយកែសម្រួលមាត្រា១ និងមាត្រា២ កាលពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ក្រោយពីគោលនយោបាយជាតិ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦-២០២៦ ត្រូវបានរាជរដ្ឋាភិបាលអនុម័តកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ ។

## ២. សកម្មភាពសម្រេចបានក្នុងខែវិច្ឆិកា ឆ្នាំ២០២០

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ សូមជូនរបាយការណ៍សមិទ្ធិផលការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២០ ដូចខាងក្រោម÷

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់បណ្តាញសង្គម និងយុទ្ធសាស្ត្រទីផ្សារ នៅខេត្តកំពង់ស្ពឺ នៅថ្ងៃទី២-៣ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលមានសិក្ខាកាមចូលរួមប្រមាណជា ១៤០នាក់។
- បានរៀបចំប្រជុំក្រុមការងារស្នូលនៃអគ្គលេខាធិការដ្ឋានភ១.ផ១ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ ពិភាក្សាលើបច្ចុប្បន្នភាពបញ្ជីឈ្មោះផលិតផលបឋមតាមរាជធានី-ខេត្ត២៥ និងពិភាក្សាលើការផ្សារភ្ជាប់ការងាររបស់ភ១.ផ១ ទៅនឹងគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច AIMs ដែលមានសមាសភាពចូលរួម ១២នាក់។

- បានប្រជុំពិភាក្សាធ្វើការកែសម្រួលវេបសាយ របស់គណៈកម្មាធិការជាតិជំរុញចលនាភូមិ១ផលិតផល១ (គ.ជ.ភ១.ផ១) www.ovopnationalcommittee.gov.kh នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ និងUploadឯកសារ និងពត៌មានការងារភ១.ផ១ជាទៀងទាត់ទៅក្នុងវេបសាយ គ.ជ.ភ១.ផ១ និង Pageផ្លូវការរបស់គ.ជ.ភ១.ផ១។
- រៀបចំកិច្ចប្រជុំរវាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ និងសហគ្រាស Wemall នៅថ្ងៃទី២0 ខែវិច្ឆិកា ឆ្នាំ២០២០ ដែលមានសមាជិកចូលរួមប្រមាណជា១៥នាក់ ពិភាក្សាលើកិច្ចសហការគ្នាក្នុងការជួយជំរុញទីផ្សារផលិតផលខ្មែរ ក្នុងប្រទេស និងទៅទីផ្សារក្រៅប្រទេស។
- បានពិគ្រោះយោបល់រវាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម លើការងារបណ្តុះបណ្តាល និងលើកកម្ពស់ផលិតផលខ្មែរលើវិស័យកសិកម្ម។

## ៣. សេចក្តីសន្និដ្ឋាន

សកម្មភាពការងារអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជំរុញចលនាភូមិ១ផលិតផល១ ទទួលបានជោគជ័យ និងសម្រេចបានតាមផែនការប្រចាំឆ្នាំ២០២០។ ការសម្រេចការងារនេះគឺពឹងផ្អែកទាំងស្រុងលើការខិតខំយកចិតទុកដាក់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់អគ្គលេខាធិការដ្ឋានភ១.ផ១ ព្រមទាំងបានការចូលរួមពីស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយរាជធានី-ខេត្ត។

**ត.ប ឧបនាយករដ្ឋមន្ត្រី**

**ប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ**

**អគ្គលេខាធិការ**

**វេជ្ជ.ជា សុំណាង**